# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៤ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកណ្តាល** ដែលមានសមាសភាពដូចខាងក្រោមៈ



www.pheakdeylaw.com

| | | |
|---|---|---|
| ១. ឯ.ឧ ប៊ិន ឈិន | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ប្រធាន |
| ២. ឯ.ឧ ស៊ុន ចាន់ថុល | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. ឯ.ឧ អូន ព័ន្ធមុនីរ័ត្ន | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯ.ឧ ប្រាក់ សុខុន | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៥. ឯ.ឧ លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៦. ឯ.ឧ ឌុល គឿន | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៧. ឯ.ឧ ស្រី ថាមរុង្គ | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៨. ឯ.ឧ សុខ ចិន្តាសោភា | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៩. ឯ.ឧ ឯម សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០. ឯ.ឧ សយ ស៊ីផុន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១១. ឯ.ឧ លី ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. ឯ.ឧ ទី សុគន្ធ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៣. ឯ.ឧ ប៊ុន សំបូរ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៤. ឯ.ឧ ថៃ នរៈសត្យា | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. ឯ.ឧ ឌុច សុវណ្ណរី | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ១៦. ឯ.ឧ ហេង តៃគ្រី | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៧. ឯ.ឧ ពិត ចំណាន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៨. ឯ.ឧ អ៊ិន ចន្ទា | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៩. ឯ.ឧ សាត សាមី | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២០. ឯ.ឧ ម៉េង សក្តិធារ៉ា | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២១. ឯ.ឧ ខៀវ មុត | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២២. ឯ.ឧ សុះ មុះសិន | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៣. ឯ.ឧ អូស្មាន ហាស្សាន់ | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៤. លោកជំទាវ ចាន់ សុខ្វាវី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២៥. ឯ.ឧ វង្សី វិស្សុត | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៦. ឯ.ឧ ភួង ស៊ីផាន | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ២៧. ឯ.ឧ ហេ កាន់ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៨. ឯ.ឧ ជា ផុន | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៩. ឯ.ឧ ឈឿន ប៊ុណ្ណារ័ត្ន | អនុរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣០. លោកជំទាវ ជួង សារុន | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៣១. លោកជំទាវ នាង ឆាយយ៉ាណា | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ៣២. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៣៣. តំណាងក្រសួងព័ត៌មាន | | សមាជិក |
| ៣៤. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |



www.pheakdeylaw.com

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តកណ្តាល និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com